Nº 2

# សិទ្ធិ និងភារកិច្ចរបស់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ

**សំណួរៈ** **តើគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិ និងភារកិច្ចយ៉ាងដូចម្តេចខ្លះ ?**

**ចម្លើយៈ** គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិ និងភារកិច្ចដូចជា ÷

-គណនយោបាយទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ មានសិទ្ធិស្នើសុំចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ។

-និងមានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញពីការសម្រេចបដិសេធ មិនយល់ព្រមចុះបញ្ជីគណបក្សនយោបាយបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់ គ.ជ.ប ។

គណបក្សនយោបាយដែលត្រូវបាន គ.ជ.ប យល់ព្រមឱ្យចុះបញ្ជីគណបក្សឈរឈ្មោះបោះឆ្នោតហើយ :

-មានសិទ្ធិធ្វើការឃោសនាបោះឆ្នោត

-មានសិទ្ធិបញ្ជូនតំណាងរបស់ខ្លួនដើម្បីសង្កេតមើលដំណើរការបោះឆ្នោត

-មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ ទាក់ទងនឹងដំណើរការបោះឆ្នោត ។

**សំណួរៈ** **ចំពោះការឃោសនាបោះឆ្នោតវិញ តើការឃោសនាបោះឆ្នោតនេះមានទិសដៅយ៉ាងដូចម្តេចខ្លះ ?**

**ចម្លើយៈ** -ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយនូវកម្មវិធីនយោបាយរបស់គណបក្សខ្លួនដល់អ្នកបោះឆ្នោតតែប៉ុណ្ណោះ ។

-ក្នុងការឃោសនា ការរិះគន់គណបក្សនយោបាយដទៃត្រូវឆ្លុះបញ្ចាំងតែទៅលើគោលនយោបាយ កម្មវិធីនយោបាយ និងបទពិសោធន៍ការងារ ។ ត្រូវចៀសវាងដាច់ខាតចំពោះការរិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ ។

**សំណួរៈ** **រាល់សេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តប័ណ្ណ ។ល។ ដែលសម្រាប់បម្រើការឃោសនា តើគណបក្សនយោបាយ និងបេក្ខជន គប្បីធ្វើយ៉ាងដូចម្តេចខ្លះ ដើម្បីបញ្ចៀសនូវអំពើហិង្សា ?**

**ចម្លើយៈ** - រាល់សេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តប័ណ្ណ រូបភាពបិទផ្សាយទាំងឡាយ និងសម្ភារៈឃោសនាផ្សេងទៀត គណបក្សនយោបាយ និងបេក្ខជនត្រូវចៀសវាងដាច់ខាតនូវការប្រើភាសា

ឬរូបភាព រំលោភបំពានខ្ទះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ បង្កឱ្យមាន បរិយាកាសតានតឹង ឬជាងនេះទៅទៀត បង្កឱ្យកើតមានអំពើហិង្សា ។ល។

- គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវទទួលខុសត្រូវផ្ទាល់លើខ្លឹមសារ និងសកម្មភាព ឃោសនាបោះឆ្នោតរបស់ខ្លួន ។

**សំណួរៈ** **ក្នុងដំណើរការរៀបចំការបោះឆ្នោត តើគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះ បោះឆ្នោត គប្បីសហការជាមួយអ្នកណាខ្លះ ?**

**ចម្លើយៈ** - គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការ រៀបចំការបោះឆ្នោតគ្រប់ថ្នាក់ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរដែនដី អ្នក សង្កេតការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ។

- គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវយកចិត្តទុកដាក់គោរពច្បាប់ បទបញ្ជា នីតិវិធីនិងក្រមសីលធម៌ និងរាល់កម្មវិធីឃោសនាទាំងអស់ ដែលសម្របសម្រួលដោយ គឃ/សប។

**សំណួរៈ** ក្នុងករណីដែលគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ពិនិត្យឃើញថា បុគ្គល ណាម្នាក់បានប្រព្រឹត្តអំពើណាមួយផ្ទុយនិងច្បាប់ បទបញ្ជា និងនីតិវិធី របស់ គ.ជ.ប ក្នុងដំណើរ ការរៀបចំការបោះឆ្នោត **តើគណបក្សនយោបាយ និង បេក្ខជនឈរឈ្មោះបោះឆ្នោត មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់បានដែរឬទេ ?**

**ចម្លើយៈ** គណបក្សនយោបាយ និងបេក្ខជនទាំងអស់មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅនឹងបុគ្គលណា ម្នាក់ដែលប្រព្រឹត្តផ្ទុយនឹងបទបញ្ជា និង នីតិវិធី គ.ជ.ប ប្រសិនបើមានភស្តុតាងបញ្ជាក់ពីអំពើ នោះ ។ ការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ ត្រូវធ្វើទៅតាមឋានានុក្រមនៃស្ថាប័ន គ.ជ.ប រហូត ដល់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**សំណួរៈ** **ចំពោះតំណាងគណបក្សនយោបាយវិញ តើតំណាងគណបក្សនយោបាយ មានសិទ្ធិ មានវត្តមាននៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានដែរ ឬទេ ?**

**ចម្លើយៈ** តំណាងគណបក្សនយោបាយមានសិទ្ធិមានវត្តមាននៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹក ឆ្នោត ដែលខ្លួនបានទទួលការអនុញ្ញាតតាមទីកន្លែង និងពេលវេលាដែលបានកំណត់ដោយគណៈ កម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**សំណួរៈ** **តើតំណាងគណបក្សនយោបាយមានសិទ្ធិចូលទៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានប៉ុន្មាននាក់ដែរ ?**

**ចម្លើយៈ** - តំណាងគណបក្សនយោបាយមានសិទ្ធិចូលទៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានតែម្នាក់ប៉ុណ្ណោះ ។ តំណាងបម្រុងនៃគណបក្សនយោបាយត្រូវរង់ចាំនៅក្រៅការិយាល័យដើម្បីជំនួសតំណាងពេញសិទ្ធិក្នុងករណីមានការផ្លាស់ប្តូរ ។

-គណបក្សនយោបាយមានសិទ្ធិផ្លាស់ប្តូរតំណាងពេញសិទ្ធិ និងតំណាងបម្រុងរបស់ខ្លួន។

**សំណួរៈ** **នៅក្នុងការិយាល័យបោះឆ្នោតឬរាប់សន្លឹកឆ្នោត តើតំណាងគណបក្សនយោបាយមានសិទ្ធិជំទាស់រាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធី ដែលខ្លួនបានឃើញផ្ទាល់ពីសំណាក់ជនណាម្នាក់បានដែរ ឬទេ ?**

**ចម្លើយៈ** - តំណាងគណបក្សនយោបាយមានសិទ្ធិជំទាស់រាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធីដែលខ្លួនបានឃើញផ្ទាល់។ ការជំទាស់ត្រូវធ្វើឡើងទៅប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់អាចលើកឡើងដោយផ្ទាល់មាត់ ឬ/ និង ទៅតាមទម្រង់បែបបទរបស់ គ.ជ.ប ។

**សំណួរៈ** **ក្រៅពីនេះ តើតំណាងគណបក្សនយោបាយ នៅមានសិទ្ធិ និងភារកិច្ចអ្វីខ្លះទៀត ?**

**ចម្លើយៈ** - ពិតជាមាន តំណាងគណបក្សនយោបាយមានសិទ្ធិចុះហត្ថលេខានៅលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗ ដែលកំណត់ដោយ គ.ជ.ប ។

- តំណាងគណបក្សនយោបាយ ដែលរួមសង្កេតការណ៍បោះឆ្នោត អាចចុះហត្ថលេខា ឬផ្តិតមេដៃនៅលើកំណត់ហេតុបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

-តំណាងគណបក្សនយោបាយមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅតាមបទបញ្ជា និង នីតិវិធី គ.ជ.ប ប្រសិនបើពិនិត្យឃើញ និងមានភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនិងច្បាប់ បទបញ្ជា និងនីតិវិធី គ.ជ.ប ក្នុងដំណើរការរៀបចំការបោះឆ្នោត ។

- តំណាងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើភាពគ្នាក្នុងការការពារសន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានា ក្នុងដំណើរការបោះឆ្នោតទាំងមូល ។